**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ..០២៨...ឧឧបសា/ឥស

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ប្រឡងប្រណាំងពាក់ព័ន្ធការឆ្លើយតប ទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញគោលនយោបាយរបស់រាជរដ្ឋាភិបាលលេខ ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី "ភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព"
- បានឃើញលិខិតលេខ ១០៧ សជណ.មយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពី ករណីសំណើសុំគោលការណ៍ដឹកនាំអំពីការអនុវត្តចលនាប្រឡងប្រណាំងគោលនយោបាយ "ភូមិ ឃុំ-សង្កាត់ មានសុវត្ថិភាព"
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការ ប្រឡងប្រណាំងពាក់ព័ន្ធការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១-ឯកឧត្តមសាស្ត្រាចារ្យ | **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | **ប្រធាន** |
| ២-ឯកឧត្តម | **ម៉ៅ សុវណ្ណ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជា អនុប្រធាន គ.ជ.គ.ម | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តមវេជ្ជបណ្ឌិត | **សាន់ សាម់អ៊ី** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-ឯកឧត្តមវេជ្ជបណ្ឌិត | **ច័ូវ ភាង** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៥-ឯកឧត្តមវេជ្ជបណ្ឌិត | **ហុក គីមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល | អនុប្រធាន |
| ៦-ឯកឧត្តមសាស្ត្រាចារ្យ | **ឈាង រ៉ា** | អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត | សមាជិក |
| ៧-ឯកឧត្តមសាស្ត្រាចារ្យ | **ទី ម៉េង** | នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ៨-ឯកឧត្តមសាស្ត្រាចារ្យរង | **លូ លីឃាង** | នាយកមន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ៩-ឯកឧត្តមសាស្ត្រាចារ្យ | **ឈា ឆវណ្ណ** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ១០-ឯកឧត្តមវេជ្ជបណ្ឌិត | **លី សូវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១១-ឯកឧត្តមសាស្ត្រាចារ្យ | **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ១២-ឯកឧត្តមវេជ្ជបណ្ឌិត | **ស៊ុំ វិនតៈ** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៣-ឯកឧត្តម | **ឃុន សុខា** | ទីប្រឹក្សា គ.ជ.គ.ម និងជាប្រធាននាយកដ្ឋាន អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល | សមាជិក |
| ១៤-លោកវេជ្ជបណ្ឌិត | **សុខ ស្រ៊ុន** | ប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ១៥-លោកស្រីវេជ្ជបណ្ឌិត | **ទូច សុខនាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ១៦-ឱសថបណ្ឌិត | **ហេង ប៊ុនគៀត** | ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង | សមាជិក |
| ១៧-លោកវេជ្ជបណ្ឌិត | **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន | សមាជិក |
| ១៨-លោកវេជ្ជបណ្ឌិត | **លី វិជ្ជារ៉ាវុធ** | ប្រធាននាយកដ្ឋានផែនការ និងព័ត៌មាន សុខាភិបាល | សមាជិក |
| ១៩-លោកស្រីបណ្ឌិត | **ឈា ឆដារ៉ា** | នាយកមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព | សមាជិក |
| ២០-លោកសាស្ត្រាចារ្យ | **តាន់ សុគុន** | នាយកមន្ទីរពេទ្យកម្ពុជា-ចិន ព្រះកុសុមៈ | សមាជិក |
| ២១-លោកសាស្ត្រាចារ្យ | **ញឹម អង្គារបុស្ស** | នាយកមន្ទីរពេទ្យកុមារជាតិ | សមាជិក |
| ២២-លោកវេជ្ជបណ្ឌិត | **ភុល ហៀវ** | ប្រធាននាយកដ្ឋានការពារសុខភាព | ប្រធានលេខាធិការ |
| ២៣-លោកស្រីវេជ្ជបណ្ឌិត | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព | អនុប្រធាន លេខាធិការអចិន្ត្រៃយ៍ |
| ២៤-លោកគ្រូពេទ្យ | **អៀង សុខគី** | ប្រធានការិយាល័យគ្រប់គ្រងគ្រោះ មហន្តរាយ និងសុខភាពបរិស្ថាន | អនុប្រធានលេខាធិការ |
| ២៥-លោក | **ខិន អាត** | អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះ មហន្តរាយ និងសុខភាពបរិស្ថាន | សមាជិក |
| ២៦-កញ្ញាវេជ្ជបណ្ឌិត | **ថុល ដារីន** | អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះ មហន្តរាយនិងសុខភាពបរិស្ថាន | សមាជិក |

២៧-តំណាងអង្គការសុខភាពពិភពលោក (WHO) សមាជិក
២៨-តំណាងអង្គការ UNICEF សមាជិក
២៩-តំណាងអង្គការ GIZ សមាជិក

**ប្រការ២.-**

គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំផែនការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា។
- រៀបចំគោលការណ៍ណែនាំចលនាប្រឡងប្រណាំងសម្រាប់ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" រាជធានី-ខេត្ត ស្តីពីការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា នៅក្នុងមូលដ្ឋានដូចជា ជំងឺកូវីដ-១៩... សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"។
- រៀបចំបណ្តុះបណ្តាល និងធ្វើលំហាត់សមយុទ្ធអំពីការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលាពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា ដល់មន្ត្រីមូលដ្ឋាន ភូមិ ឃុំ សង្កាត់។
- ធ្វើការតាមដាន និងវាយតម្លៃប្រចាំឆ្នាំលើចលនាប្រឡងប្រណាំងក្នុងការអនុវត្តត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានានៅតាម "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" រាជធានី-ខេត្ត ។

**ប្រការ៣.-**

សមាជិកគណៈកម្មការដើម្បីរៀបចំការអនុវត្តចលនាប្រឡងប្រណាំងគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ត្រូវបំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការក្រសួងសុខាភិបាល នាយកដ្ឋានការពារសុខភាព នាយកដ្ឋានពាក់ព័ន្ធ មជ្ឈមណ្ឌលជាតិ វិទ្យាស្ថានជាតិ មន្ទីរពេទ្យជាតិ អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល និងអង្គការដៃគូ និងសាមីខ្លួន ដូចមាននៅក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៤រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២១

ម៉ម_ប៊ុនហេង

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គាធិការក្រសួងសុខាភិបាល
- នាយកដ្ឋានពាក់ព័ន្ធ
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព
- មន្ទីរពេទ្យជាតិ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ